## បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (genocide)

អំពើប្រល័យពូជសាសន៍ ជាការបព្រឹត្ត នូវទង្វើកំណត់ជាក់លាក់ណាមួយ មានចេតនាក្នុងការបំផ្លាញក្រុមមនុស្ស ពូជសាសន៍ ជាតិ ឬសាសនា។ បទប្រល័យពូជសាសន៍ ពីដំបូងជា ផ្នែកមួយនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity)។

ឆ្នាំ ១៩៤៨ មានអនុសញ្ញា ស្តីពី ការបង្ក្រាបអំពើប្រល័ពូជសាសន៍ ដែលបានចែងលម្អិតក្នុងមាត្រា ២ ដូចជា ការសម្លាប់សមាជិកក្រុម ការដាក់វិធានបង្អាក់កំណើតមនុស្សក្នុងក្រុម...។ បទប្បញ្ញាតិ សំដៅលើការបំផ្លាញក្រុមមនុស្សបួនប្រភេទខាងលើ។ ក្រុមប្រជាជាតិ (national group) សំដៅលើក្រុមមានសញ្ជាតិ ឬដើមកំណើតសង្គម។ ក្រុមពូជសាសន៍ (racial group) សំដៅក្រុមមានសណ្ឋានរូបកាយពូជពង្ស ដូចជាផ្អែកលើព៌ណសម្បុរ។ រីឯក្រុមជាតិពន្ធុ (ethnic group) ផ្តោតលើប្រពៃណី និងភាសា និងចុងក្រោយ ក្រុមសាសនា ដែលមានជំនឿ និងវិធីសក្ការៈដូចគ្នា។ ជាការពិត និយមន័យ ស្តីពីក្រុមទាំងបួន អាចមានខ្លឹមសារជាន់គ្នា ដូចនេះ វាគ្រាន់តែជាសញ្ញាណប៉ុណ្ណោះ សម្រាប់បែងចែកប្រភេទនៃក្រុម។

មានការយល់ច្រឡំគ្នា រវាងអំពើប្រល័យពូជសាសន៍ នឹងការសម្លាប់ទ្រង់ទ្រាយធំ (mass killing/extermination)។

ធាតុផ្សំអត្តនោម័តសម្រាប់បទប្រល័យពូជសាសន៍ គឺចេតនាជាក់លាក់ (specific intent) ដែលអាចបង្ហាញតាមរយៈភស្តុតាង ដោយផ្ទាល់ ឬប្រយោល (circumstantial evidence)។ ក្នុងន័យនេះ គោលនយោបាយ ប្រល័យពូជសាសន៍ ដែលជានិច្ចកាល ត្រូវបានទាមទារ ជាភស្តុតាងដ៏សំខាន់មួយ។ សកម្មភាព ឬទង្វើ អាចជាការបំបាត់ភាពជាបុគ្គលនៃក្រុមមនុស្ស (depersonalizing of victim) ដែលសំដៅលើការបំផ្លាញក្រុមមនុស្ស (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 332-336)។

**ខ្លឹមសារបន្ថែម៖** កម្ពុជា បានចូលជាភាគីនៃ អនុសញ្ញានេះ ក្នុងឆ្នាំ ១៩៥០ ។ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ បានសរសេរបញ្ចូលនូវបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងមាត្រា ១៨៣។